ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តបន្ទាយមានជ័យ
លេខ៖ ៦២៥/២០ សរជណ

ថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

បន្ទាយមានជ័យ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១

យោងលិខិតលេខ០០១ សណជ/គជអប ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)សេចក្ដីណែនាំក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១ ។

រដ្ឋបាលខេត្តបន្ទាយមានជ័យ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (សំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ទ្វារទឹកខ្នាតតូច ផ្លូវដីស ផ្លូវក្រួសក្រហម លូមូល...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្ដូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខាគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងយ៉ាងតិច០២ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការនិងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលរាជធានី ខេត្តដើម្បីពិនិត្យ និងសម្រេច។

អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមអញ្ជើញមកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង១៧.០០នាទីល្ងាច ។ ចំពោះអ្នកទទួលការដែល

មានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត ដោយឥតបង់ថ្លៃ តាមអាសយដ្ឋានអគារជួរក្រោយក្នុងបរិវេណសាលាខេត្តបន្ទាយមានជ័យ។

**អភិបាលខេត្ត**

**អ៊ុំ រាត្រី**

**ចម្លងជូន**

-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-លេខាធិការដ្ឋាន គ.ជ.អ.ប
-ក្រុមប្រឹក្សាខេត្ត
«ដើម្បីគោរពជូនជ្រាប»
-គ្រប់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
«ដើម្បីផ្សព្វផ្សាយ»
-ឯកសារ-កាលប្បវត្តិ